អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- ការប្រមូលចំណូលពន្ធពីវិស័យកាស៊ីណូបានធ្លាក់ចុះជាង ៥០%
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអនុម័តកញ្ចប់វិនិយោគថ្មី ដែលមានទឹកប្រាក់ប្រមាណជិត ៧០លានដុល្លារ
- អ្នកបង់ពន្ធសាជីវកម្មដែលជាប់ចំណាត់ថ្នាក់ខ្ពស់ត្រូវបានទទួលការលើកទឹកចិត្ត
- ការចំណាយលើអត្ថប្រយោជន៍សង្គមនៅក្នុងឆមាសទី២ ឆ្នាំ២០២០
- វិស័យផលផលរៀតណាមត្រូវបានមើលឃើញថា នឹងក្លាយជាវិស័យសេដ្ឋកិច្ចដ៏មានសារៈសំខាន់មួយ
- ប្រទេសថៃសម្រេចកាត់បន្ថយរយៈពេលធ្វើចត្តាឡីស័ក ដើម្បីជួយសម្រួលដល់វិស័យសេដ្ឋកិច្ចដែលរងផលប៉ះពាល់
- ធនាគារកណ្តាលមើលឃើញពីកំណើនសេដ្ឋកិច្ចរឹងមាំ និងអតិផរណាខ្ពស់ ប៉ុន្តែមិនមានការដំឡើងអត្រាការប្រាក់
- ប្រាក់ម្ចីរបស់រដ្ឋាភិបាលចក្រភពអង់គ្លេស (UK) ឡើងដល់កម្រិតខ្ពស់នៅក្នុងខែកុម្ភៈ ដោយសារបន្តរងឥទ្ធិពលនៃជំងឺរាតត្បាត

ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

ចងក្រង និងបូកសរុបដោយ

- ធីម ប៊ុនធឿន ប្រធានការិយាល័យវិភាគចំណូល-ចំណាយ

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការប្រមូលចំណូលពន្ធពីវិស័យកាស៊ីណូបានធ្លាក់ចុះជាង ៥០%




*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១, រូបភាព៖ ហុង មិនា*

យោងតាមលោក រស់ ភិរុណ អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានលើកឡើងថា៖ ការប្រមូលចំណូលពន្ធពីវិស័យកាស៊ីណូ ក្នុងឆ្នាំ២០២០ សម្រេចបានថវិកាចំនួន ៤០ លានដុល្លារ ធ្លាក់ចុះជាង ៥០% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៩។ ការធ្លាក់ចុះនៃការប្រមូលចំណូលពន្ធនេះ ដោយសារតែការរីករាលដាលនៃជំងឺកូវីដ-១៩ ជាសកល ចាប់តាំងពីចុងឆ្នាំ២០១៩ នឹងបន្តអូសបន្លាយរហូតមកដល់បច្ចុប្បន្ន ដែលធ្វើឱ្យប៉ះពាល់ស្ទើរគ្រប់វិស័យ ជាពិសេសប៉ះពាល់យ៉ាងខ្លាំងទៅដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរណ៍បរទេសមកកាន់ប្រទេសកម្ពុជា។ វិស័យឧស្សាហកម្មកាស៊ីណូ ក៏រងផលប៉ះពាល់ខ្លាំង ពេលគឺប្រតិបត្តិការកាស៊ីណូស្ទើរទាំងស្រុងត្រូវបានបិទនៅក្នុងឆ្នាំ២០២០។ មានតែកាស៊ីណូប្រមាណជា ៧ ទៅ ៨ ប៉ុណ្ណោះ ដែលបានដំណើរការអាជីវកម្មរបស់ខ្លួន។ បន្ថែមពីនេះ ការបិទសកម្មភាពល្បែងតាមអនឡាញ និងការផ្អាកប្រតិបត្តិការកាស៊ីណូ កាលពីខែមេសា ឆ្នាំ២០២០ ជាផ្នែកមួយ ធ្វើឱ្យការប្រមូលចំណូលពន្ធ មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់។

ទន្ទឹមនឹងនេះ ការប្រមូលចំណូលពន្ធពីឧស្សាហកម្មកាស៊ីណូ ត្រូវបានគេរំពឹងថានឹងកើនឡើងទ្វេដង នៅក្នុងឆ្នាំ២០២១នេះ ដោយសារការអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ដែលបានអនុម័ត និងដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ កន្លងមក តាមរយៈការប្រមូលចំណូលពន្ធប្រកបដោយតម្លាភាព តែប្រសិនបើជំងឺកូវីដ-១៩ នៅតែបន្តនូវការរីករាលដាល គេមិនហ៊ានព្យាករណ៍ថាចំណូលពីវិស័យនេះ នឹងអាចដំណើរការបានល្អនោះទេ។

គិតត្រឹមខែមីនា ឆ្នាំ២០២១ កម្ពុជាមានក្រុមហ៊ុនកាស៊ីណូចំនួន១០១ បានដាក់ពាក្យបន្តអាជ្ញាប័ណ្ណក្នុងចំណោមកាស៊ីណូសរុបចំនួន ១៩៣ នៅត្រឹមដំណាច់ឆ្នាំ២០២០៕

*ដោយសេន ចន្ទូ*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១*

## ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអនុម័តកញ្ចប់វិនិយោគថ្មី ដែលមានទឹកប្រាក់ប្រមាណជិត ៧០លានដុល្លារ




*ប្រភព៖ Khmer Times ២០២១, រូបភាព៖ KT/Husain Haider*

កាលពីថ្ងៃសុក្រ សប្ដាហ៍មុន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានអនុម័តទឹកប្រាក់ប្រមាណ៧០លានដុល្លារ សម្រាប់ការវិនិយោគរបស់រោងចក្រថ្មីៗ ចំនួន ៧ ដែលអាចផ្ដល់ការងារជូនប្រជាពលរដ្ឋបានជាង ២ ៦០០ កន្លែង។

ក្នុងចំណោមការវិនិយោគសរុបទាំងនោះ ខេត្តព្រះសីហនុ ទទួលបានការវិនិយោគក្នុងទំហំប្រមាណជា ១០លានដុល្លារ តាមរយៈការវិនិយោគរបស់រោងចក្រមួយឈ្មោះ ថៃ Innomed Healthcare Products (Cambodia) Co Ltd ហើយដែលនឹង អាចផ្ដល់ការងារជូនប្រជាពលរដ្ឋបាន ១ ២០០នាក់ ខណៈដែលខេត្តកណ្ដាល នឹងទទួលបាន ការវិនិយោគរបស់ក្រុមហ៊ុន First Aquatic Industrial Co Ltd ក្នុងទំហំទឹកប្រាក់ប្រមាណជា ២៥,២លានដុល្លារ។

រីឯខេត្តស្វាយរៀងទទួលបានការវិនិយោគ ក្នុងទំហំប្រហែលជា ២៤,៦លានដុល្លារ តាមរយៈការវិនិយោគរបស់ក្រុមហ៊ុន Huiquangfeng Technology (Cambodia) Co Ltd និងក្រុមហ៊ុន Green Sustainable Ventures (Cambodia) Co Ltd (GSV)។ ក្រុមហ៊ុនទាំងពីរនេះអាចផ្ដល់ការងារជូនប្រជាពលរដ្ឋបាន ៣៣០កន្លែង។ ដោយឡែកនៅរាជធានីភ្នំពេញ ខណ្ឌសែនសុខ ទទួលបានការវិនិយោគនេះ ក្នុងទំហំទឹកប្រាក់ប្រមាណជា ២,៩ លានដុល្លារ តាមរយៈការវិនិយោគរបស់ក្រុមហ៊ុនឈ្មោះ Xin Wei Jie Co Ltd ដែលអាចផ្ដល់ការងារជូនប្រជាពលរដ្ឋបានចំនួន ៦៥៩កន្លែង។

ទន្ទឹមនឹងនេះដែរ ខេត្តពោធិ៍សាត់ទទួលបាន ការវិនិយោគក្នុងទំហំទឹកប្រាក់ចំនួន ២,៥លានដុល្លារ តាមរយៈការវិនិយោគរបស់ក្រុមហ៊ុនឈ្មោះ Schneitic Chint Co Ltd ដែលអាចផ្ដល់ការងារជូនប្រជាពលរដ្ឋចំនួន ៦២កន្លែង។ ចំណែកឯ ខេត្តតាកែវទទួលបានការវិនិយោគក្នុងទំហំទឹកប្រាក់ ២,២លានដុល្លារ នឹងអាចបង្កើតការងារជូនប្រជាពលរដ្ឋនៅស្រុកត្រាំកក់បាន ២៣២ កន្លែង៕ *ដោយ វង្ស ច័ន្ទស្នីដារា*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១*

## អ្នកបង់ពន្ធសាជីវកម្មដែលជាប់ចំណាត់ថ្នាក់ខ្ពស់ត្រូវបានទទួលការលើកទឹកចិត្ត



*ប្រភព៖ Khmer Times ២០២១*

ឯកឧត្តម គង់ វិបុល មានប្រសាសន៍ថា៖ ការប្រកាសពន្ធ និងការពង្រឹងអភិបាលកិច្ច និងតម្លាភាពនៅក្នុងការបង់ពន្ធ គឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា។ គួររំលឹកថា ការប្រមូលពន្ធលើប្រាក់ចំណូលនៅក្នុងឆ្នាំ ២០២០ មានទំហំប្រមាណជា ២,៨៨៩ប៊ីលានដុល្លារ កើនឡើងជាងឆ្នាំ២០១៩ ចំនួន៣,៧%។ ទន្ទឹមនឹងនេះ ចំណូលពន្ធដែលប្រមូលបានពីវិស័យធនាគារ នៅក្នុងឆ្នាំ២០២០ មានទឹកប្រាក់ប្រហែលជា ៥៣លានដុល្លារ។

នៅក្នុងឆ្នាំ២០១៩ អ្នកបង់ពន្ធសាជីវកម្មធំៗ ទទួលបានវិញ្ញាបនបត្រកោតសរសើរពី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អូន ព័ន្ធមុនីរ័ត្ន។

ថ្មីៗនេះ ឯកឧត្តម គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានប្រកាសឈ្មោះក្រុមហ៊ុនសាជីវកម្មចំនួន ៣០ ដែលទទួលបានចំណាត់ថ្នាក់ខ្ពស់នៅក្នុងការបង់ពន្ធសាជីវកម្ម និងទទួលបានវិញ្ញាបនបត្រពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។ ក្នុងនោះ មានក្រុមហ៊ុនសាជីវកម្មចំនួន ១០ ដែលទទួលបានចំណាត់ថ្នាក់ខ្ពស់ជាងគេប្រចាំឆ្នាំគឺ៖ Heineken Cambodia, PRASAC Microfinance Institution, Khmer Beverages Co Ltd, ACLEDA Bank, Viettel (Cambodia) Pte Ltd, Smart Axiata, N.C.X. Co Ltd, Electricite du Cambodge(EDC), Canadia Bank Plc and SCA (Societe Concessionnaire des Aeroports)។

នៅក្នុងចំណោមនោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ក៏ទទួលបានចំណាត់ថ្នាក់ខ្ពស់នៅក្នុងការបង់ពន្ធសាជីវកម្មដែរ។ លោក សាយ សូនី អនុប្រធាននាយកប្រតិបត្តិ និងប្រធានផ្នែកទីផ្សាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ បានបង្ហាញចំណាប់អារម្មណ៍ថា ការគោរពកាតព្វកិច្ចបង់ពន្ធរបស់ប្រាសាក់ បានចូលរួមចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិដោយផ្ទាល់ និងដោយប្រយោល។ ដោយឡែក លោកស្រី ម៉ា អមរា អនុប្រធានប្រតិបត្តិ និងជាប្រធានក្រុមមន្ត្រីហិរញ្ញវត្ថុ របស់ធនាគារអេស៊ីលីដា បានថ្លែងយ៉ាងដូច្នេះថា ចំណូលសារពើពន្ធ គឺជាចំណូលចម្បងរបស់រដ្ឋ។ ប្រសិនបើរដ្ឋប្រមូលចំណូលពន្ធបានកាន់តែច្រើន ការរួមចំណែកនៅក្នុងការអភិវឌ្ឍប្រទេស ក៏កាន់តែធំទៅតាមនោះដែរ។ លោកស្រីបានបន្ថែមថា កាតព្វកិច្ចបង់ពន្ធ គឺជា

ការចូលរួមចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម៕ *ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍៖ ការចំណាយលើអត្ថប្រយោជន៍សង្គមនៅក្នុងឆមាសទី២ ឆ្នាំ២០២០

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា៖ នៅក្នុងឆមាសទី២ ឆ្នាំ២០២០ រដ្ឋបាលថ្នាក់ជាតិបានចំណាយលើអត្ថប្រយោជន៍សង្គម មានទំហំទឹកប្រាក់សរុប ១ ០០៥,១ប៊ីលានរៀល ដែលមានកំណើនប្រមាណជា ៤%។

កំណើននៃការចំណាយនេះ គឺដោយសាររាជរដ្ឋាភិបាលបានប្រើប្រាស់ថវិកា ដើម្បីជួយក្នុងការដោះស្រាយផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ ទៅលើវិស័យសុខាភិបាល សង្គម និងសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។

ជាក់ស្តែង ការចំណាយលើការឧបត្ថម្ភអង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ មានទំហំទឹកប្រាក់ ៦៥,៦ប៊ីលានរៀល នៅក្នុងឆមាសទី២ឆ្នាំ២០២០ ដែលមានកំណើនយ៉ាងខ្លាំងរហូតដល់ ៥៦% បើធៀបនឹងឆមាសទី១។

លើសពីនេះទៅទៀត ការចំណាយអត្ថប្រយោជន៍សង្គមផ្សេងៗទៀត មានទំហំទឹកប្រាក់ចំនួន ៨ប៊ីលានរៀល មានកំណើនគួរកត់សម្គាល់ប្រមាណជា ៤៦% បើធៀបនឹងឆមាសទី១។ ស្របពេលនោះដែរ ការចំណាយលើការជួយដល់ប្រជាពលរដ្ឋ មានទឹកប្រាក់ចំនួន ៤៥៩,១ ប៊ីលានរៀល នៅក្នុងឆមាសទី២ ឆ្នាំ២០២០ ដែលមានកំណើនប្រមាណជា ៧%។

ទោះបីយ៉ាងណាក៏ដោយ ការចំណាយលើអត្ថប្រយោជន៍សន្តិសុខសង្គមមានទឹកប្រាក់ចំនួន ៥១៦,៥ប៊ីលានរៀល នៅក្នុងឆមាសទី២ ឆ្នាំ២០២០ ដែលធ្លាក់ចុះបន្តិចប្រមាណជា ៣% បើធៀបនឹងឆមាសទី១៕ *ដោយ មិត្ត ចន្ទី*

| ការចំណាយឆ្នាំ២០២០ (គិតជាប៊ីលានរៀល) | ឆមាសទី១ | ឆមាទី២ | កំណើន/ថយ(%) |
|---|---|---|---|
| **អត្ថប្រយោជន៍សង្គម** | **1,005.1** | **1,049.2** | **4%** |
| អត្ថប្រយោជន៍សន្តិសុខសង្គម | 530.0 | 516.5 | -3% |
| ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 427.5 | 459.1 | 7% |
| ឧបត្ថមអង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ | 42.0 | 65.6 | 56% |
| អត្ថប្រយោជន៍សង្គមផ្សេងៗទៀត | 5.6 | 8.0 | 43% |

*ប្រភព៖តារាងប្រតិបត្តិការហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### វិស័យផលិតផលត្រីវៀតណាម ត្រូវបានមើលឃើញថា នឹងក្លាយជាវិស័យសេដ្ឋកិច្ចដ៏មានសារៈសំខាន់មួយ



*ប្រភព៖ Vietnem+ ២០២១, រូបថត៖ VNA*

ស្ថិតក្រោមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យជលផល ទៅដល់ឆ្នាំ ២០៣០ និងចក្ខុវិស័យ ឆ្នាំ២០៤៥ ដែលត្រូវបានអនុម័ត ដោយនាយករដ្ឋមន្ត្រីវៀតណាមថ្មីៗនេះ បានបង្ហាញឱ្យឃើញថា ត្រឹមឆ្នាំ២០៣០ វិស័យជលផលនឹងត្រូវញែកចេញ និងចាត់ទុកជាវិស័យសេដ្ឋកិច្ចដ៏សំខាន់មួយសម្រាប់ប្រទេសវៀតណាម។ ដោយឡែក ដើម្បីសម្រេចបានគោលដៅដែលបានចែងក្នុងយុទ្ធសាស្ត្រនេះ វិស័យជលផល ត្រូវធ្វើការពង្រឹងបន្ថែម ដោយផ្តោតលើការអភិវឌ្ឍផលិតកម្មទំនិញក្នុងទ្រង់ទ្រាយធំ តាមរយៈការរួមផ្សំរវាងឧស្សាហូបនីយកម្ម ជាមួយនឹងទំនើបភាវូបនីយកម្ម ការពង្រីកការប្រើប្រាស់បច្ចេកវិទ្យាទំនើបទៅក្នុងផលិតកម្ម ការរៀបចំឡើងវិញនៃរចនាសម្ព័ន្ធការផលិតដើម្បីពង្រឹងផលិតភាព និងការកសាងកិត្យានុភាពនៃកេរ្តិ៍ឈ្មោះពាណិជ្ជកម្ម(Trademarks) និងឧត្តមភាពលើគូប្រកួតប្រជែង។

ក្នុងនោះដែរ យុទ្ធសាស្ត្រនេះ បានដាក់ចេញនូវគោលដៅនៅត្រឹមឆ្នាំ២០៣០ រួមមាន៖ កំណើននៃតម្លៃផលិតកម្មនេសាទ ជាមធ្យមពី៣ ទៅ ៤% ក្នុងមួយឆ្នាំ ដែលមានផលិតផលជលផលសរុប កើនដល់ ៩,៨លានតោន (ក្នុងនោះរួមបញ្ចូលទាំង ៧លានតោនពីវារីវប្បកម្ម) និងចំណូលពីការនាំចេញចំនួន១៤ ទៅ១៦ប៊ីលានដុល្លារ។ បន្ថែមពីនេះ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យជលផល ក៏បានបង្ហាញថា ការងារច្រើនជាង ៣,៥លានការងារ ត្រូវបានបង្កើតក្នុងវិស័យជលផលនេះ ហើយអាចផ្តល់ចំណូលសម្រាប់មនុស្សម្នាក់ គឺស្មើនឹងកម្រិតថ្នាក់ជាតិ។

ទន្ទឹមនេះ អាទិភាពត្រូវបានផ្តល់ដល់ការនេសាទដែលផ្តល់តម្លៃសេដ្ឋកិច្ចខ្ពស់ រីឯកូតានេសាទ នឹងត្រូវបានបែងចែក ដើម្បីកាត់បន្ថយ និងបញ្ឈប់សកម្មភាពបំផ្លិចបំផ្លាញធនធានជលផល។ ម្យ៉ាងទៀត រដ្ឋាភិបាលនឹងពន្លឿនការធ្វើប្រតិភូកម្មលើការគ្រប់គ្រងអង្គភាពសហគមន៍ នៅតាមតំបន់ឆ្នេរ និងតំបន់ទឹកសាប៕

*ដោយ ជា សិរីរតន៍*

*ប្រភព៖ Vietnam+ ចេញផ្សាយ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១*

## ប្រទេសថៃសម្រេចកាត់បន្ថយរយៈពេលធ្វើចត្តាឡីស័ក ដើម្បីជួយសម្រួលដល់វិស័យសេដ្ឋកិច្ចដែលរងផលប៉ះពាល់


WHICH COUNTRIES ARE OPEN FOR INTERNATIONAL ARRIVALS

| | Country | Tourism receipts (million US$)* | Borders open for international tourists (yes/no) | Mandatory quarantine (yes/no) |
|---|---|---|---|---|
| 1 | USA | 256,145 | Yes | Yes |
| 2 | Spain | 81,250 | Yes | Yes and No** |
| 3 | France | 73,125 | Yes | Yes |
| 4 | **Thailand** | **65,242** | **Yes** | **Yes** |
| 5 | Germany | 60,260 | No | Yes |
| 6 | Italy | 51,602 | Yes | Yes and No** |
| 7 | UK | 48,515 | Yes | Yes |
| 8 | Australia | 47,327 | No | Yes |
| 9 | Japan | 45,276 | Yes | Yes |
| 10 | Hong Kong | 41,870 | Yes | Yes |

*Countries worldwide with the highest tourism receipts, data as of 2018.
**No quarantine measures in place for travellers arriving from the EU, Schengen member states and a list of approved third countries.

Sources: World Tourism Organization, We Go and World Nomads    BANGKOK POST GRAPHICS

*ប្រភព៖ Bangkok Post ២០២០, Bangkok Post Graphics*

យោងតាមមជ្ឈមណ្ឌលគ្រប់គ្រងស្ថានភាពជំងឺកូវីដ-១៩ របស់ថៃ (Center for the Covid-19 Situation Administration ឬ CCSA) បានប្រកាសពីការកាត់បន្ថយរយៈពេលនៃការធ្វើចត្តាឡីស័ក ពី២សប្តាហ៍ មកត្រឹម១០ថ្ងៃ ដែលមានសុពលភាពចាប់ពីខែមេសានេះទៅ និងកំពុងតែធ្វើការពិចារណាលើការកាត់បន្ថយមក

ត្រឹម៧ថ្ងៃ ចំពោះអ្នកទេសចរដែលបានចាក់វ៉ាក់សាំងរួចរាល់។ ដោយឡែក វិធានការណ៍សម្រួលនេះ មិនត្រូវបានអនុវត្តចំពោះអ្នកទេសចរ ដែលមកពីប្រទេសមានករណីជំងឺកូវីដ-១៩ បម្លែងថ្មីនោះឡើយ។ វិធានការនេះត្រូវបានធ្វើឡើង ដើម្បីជួយគាំទ្រដល់វិស័យទេសចរណ៍ដែលទន់ខ្សោយ និងការងើបឡើងវិញរបស់សេដ្ឋកិច្ច។

បន្ថែមពីនេះទៀត ចាប់ពីខែតុលានេះតទៅចំពោះអ្នកទេសចរណ៍មកពីប្រទេស ដែលមិនមានករណីជំងឺកូវីដ-១៩បម្លែងថ្មី នឹងមិនតម្រូវឱ្យធ្វើចត្តាឡីស័កនោះឡើយ។ ការធ្វើចត្តាឡីស័ករយៈពេលខ្លី ត្រូវបានរំពឹងថា នឹងអាចទាក់ទាញភ្ញៀវទេសចរ ម្យ៉ាងវិស័យនេះ គឺមានសារៈសំខាន់ណាស់ ចំពោះការងើបឡើងវិញរបស់សេដ្ឋកិច្ច ដោយសារតែវិស័យនេះ បានរួមចំណែកច្រើនជាង ១៥% នៃសេដ្ឋកិច្ចថៃ៕ *ដោយ ជា សិរីតែន៍*

*ប្រភព៖ XINHUANET ចេញផ្សាយ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### ធនាគារកណ្តាលមើលឃើញពីកំណើនសេដ្ឋកិច្ចរឹងមាំ និងអតិផរណាខ្ពស់ ប៉ុន្តែមិនមានការដំឡើងអត្រាការប្រាក់



*ប្រភព៖ CNBCNews 2021, រូបថត៖ Kevin Lamarque*

យោងតាមលោក Jerome Powell ប្រធានធនាគារកណ្តាលបានមានប្រសាសន៍ កាលពីថ្ងៃពុធថា៖ ធនាគារកណ្តាលបានបង្កើនការរំពឹងទុករបស់ខ្លួនចំពោះកំណើនសេដ្ឋកិច្ច ប៉ុន្តែបាន បង្ហាញថា មិនមានការដំឡើងអត្រាការប្រាក់ទេ រហូតដល់ឆ្នាំ២០២៣ ទោះបីជាសេដ្ឋកិច្ចមានចក្ខុវិស័យល្អប្រសើរ ហើយអតិផរណាឆ្នាំនេះមានអត្រាខ្ពស់ក៏ដោយ។

សូចនាករសកម្មភាពសេដ្ឋកិច្ច និងភាពមានការងារធ្វើបានកើនឡើងនាពេលថ្មីៗនេះ បើទោះបី បានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ នឹងមានភាពទន់ខ្សោយដោយសារតែមានជំងឺឆ្លងរាតត្បាតក៏ដោយ។ ចំណែកឯអតិផរណានៅតែបន្តក្រោមអត្រា ២% ដដែល។

បន្ថែមពីនេះ គណៈកម្មាធិការគោលនយោបាយទីផ្សារធនាគារកណ្តាល (The policymaking Federal Open Market Committee (FOMC)) ភាគច្រើនរំពឹងថា អត្រាការប្រាក់កម្ចីរយៈពេលខ្លីនៅថេរ និងខិតជិតសូន្យ រហូតដល់ឆ្នាំ២០២៣។

ផលិតផលក្នុងស្រុកសរុប(ផ.ស.ស.)ត្រូវបានគេរំពឹងថានឹងកើនឡើងដល់ ៦,៥% នៅក្នុងឆ្នាំ២០២១ ពោលគឺកើនឡើងពី ៤,២% នេះបើយោងតាមការព្យាករណ៍កាលពីខែធ្នូ ឆ្នាំ២០២០ កន្លងទៅ។

ទន្ទឹមនឹងកំណើន ផ.ស.ស. អត្រាគ្មានការងារធ្វើ នឹងធ្លាក់ចុះរហូតដល់ ៤,៥% ពីកម្រិត ៦,២% នាពេលបច្ចុប្បន្ន ធៀបនឹងការប៉ាន់ស្មានរបស់(FOMC) គឺ ៥%

កាលពីខែធ្នូ ហើយការព្យាករណ៍សម្រាប់រយៈពេលពីរឆ្នាំបន្តទៀត(២០២២-២០២៣) គឺ ៤,២% និង ៣,៧% រៀងគ្នា មុនពេលឈានដល់កម្រិតខ្ពស់ជាង៤%។

ការរំពឹងទុកសម្រាប់អតិផរណាស្នូល(Core inflation) គឺកើនឡើងរហូតដល់២,២% ក្នុងឆ្នាំ២០២១នេះ។ សម្រាប់ឆ្នាំ២០២២ នឹងធ្លាក់ចុះមកត្រឹម ២% ហើយការរំពឹងទុករយៈពេលវែងគឺ ២%។

ការព្យាករណ៍នៃការឡើងខ្ពស់នៃអតិផរណា ក្នុងឆ្នាំនេះ ដោយសារ ការប្រៀបធៀបពីឆ្នាំមួយទៅឆ្នាំមួយ(Year-over-Year) បានគិតចាប់ពីថ្ងៃដំបូងនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងដើមឆ្នាំ២០២០មក។

*ដោយ មុំ ចិន្តា*

*ប្រភព៖ CNBC ចេញផ្សាយថ្ងៃ១៧ ខែមីនា ឆ្នាំ ២០២១*

## ប្រាក់ម្ចីរបស់រដ្ឋាភិបាលចក្រភពអង់គ្លេស (UK) ឡើងដល់កម្រិតខ្ពស់នៅក្នុងខែកុម្ភៈ ដោយសារបន្តរងឥទ្ធិពលនៃជំងឺរាតត្បាត




*ប្រភព៖ BBC News, ២០២១*

រដ្ឋាភិបាលចក្រភពអង់គ្លេស (UK) បានបង្កើតកំណត់ត្រាថ្មីនៃកម្រិតប្រាក់កម្ចីរបស់ខ្លួន កាលពីខែកុម្ភៈ ដែលឆ្លុះបញ្ចាំងពីការចំណាយក្នុងការទ្រទ្រង់សេដ្ឋកិច្ចរបស់ខ្លួនក្នុងអំឡុងពេលមានវិបត្តិដោយជំងឺកូវីដ-១៩។

ក្នុងខែកុម្ភៈកន្លងទៅនេះ កម្ចីរបស់រដ្ឋាភិបាល UK បានឈានដល់ទៅ១៩,១ប៊ីលានផោន ដែលជាតួលេខខ្ពស់បំផុតសម្រាប់ខែកុម្ភៈ បើគិតតាំងពីការចាប់ផ្ដើមកំណត់ត្រាក្នុងឆ្នាំ១៩៩៣ មក។ ទោះបីយ៉ាងណាក៏ដោយ តួលេខនៃប្រាក់កម្ចីនៅក្នុងខែកុម្ភៈ (ភាពខុសគ្នារវាងចំណាយ និងចំណូលផ្នែកពន្ធដារ) មិនខ្ពស់ដូចការព្យាករណ៍របស់អ្នកសេដ្ឋកិច្ចមួយចំនួននោះទេ។

ការខ្ចីតាំងពីដើមឆ្នាំសារពើពន្ធ(ខែមេសា ២០២០ ដល់ខែមីនា ២០២១) រហូតមកទល់ពេលនេះ ពោលគឺខែមេសា ដល់ ខែកុម្ភៈនេះ ឈានដល់ ២៧៨,៨ ប៊ីលានផោន នេះបើយោងតាមការិយាល័យស្ថិតិជាតិ។

ប្រមុខរដ្ឋាភិបាល លោក Rishi Sunak បានលើកឡើងថា៖ ជំងឺកូវីដ-១៩ បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចធំបំផុតដែល UK បានកំពុងជួបប្រទះនៅពេលនេះ ដែលជាមូលហេតុ ធ្វើឱ្យរដ្ឋាភិបាលចាត់វិធានការឆ្លើយតបជាមួយនឹងកញ្ចប់ជំនួយរហូតដល់ទៅ ៣៥២ ប៊ីលានផោន ដើម្បីការពារជីវិត ព្រមទាំងជីវភាពរស់នៅរបស់ប្រជាជន។ លោកបន្តថា "នេះគឺជាការងារមួយដែលយើងត្រូវទទួលខុសត្រូវខ្ពស់ និងជាមធ្យោបាយល្អបំផុត ដើម្បីគាំទ្រដល់ហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេលមួយសមស្រប"។ ក្នុងនោះផងដែរ រដ្ឋាភិបាលបានចំណាយប្រាក់ចំនួន ៣៩ប៊ីលានផោន នៅក្នុងខែកុម្ភៈកន្លងផុតទៅដើម្បីជួយគាំទ្រដល់ការងារ និងអាជីវកម្មខ្នាតតូច។

បំណុលក្នុងវិស័យសាធារណៈសរុប បានកើនឡើងដល់ ២,១៣ប៊ីលានអឺរ៉ូ តួលេខនេះ ស្មើរតែលើសទំហំសេដ្ឋកិច្ចអង់គ្លេស ដោយបំណុលទាំងនេះបានឡើងរហូតដល់ ៩៧,៥% នៃសេដ្ឋកិច្ចប្រចាំឆ្នាំ(ផ.ស.ស.) ហើយនេះជាកម្រិតបំណុលឡើងខ្ពស់ដែលមិនធ្លាប់មាន ចាប់តាំងពីដើមទសវត្សឆ្នាំ១៩៦០មកម្លេះ បើយោងតាមការិយាល័យស្ថិតិជាតិ។ *ដោយ មុំ ចិន្តា*

*ប្រភព៖ BBC ចេញផ្សាយថ្ងៃ២០ ខែមីនា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ ការផ្តល់ប្រាក់កម្ចីសុទ្ធដល់វិស័យឯកជននៅចក្រភពអង់គ្លេស ការផ្តល់ប្រាក់កម្ចីរបស់ធនាគារនៅប្រទេសប្រេស៊ីល ការផ្គត់ផ្គង់សាច់ប្រាក់ M៣ នៅប្រទេសអាហ្វ្រិកខាងត្បូង ទស្សនៈឧស្សាហកម្មនៅតំបន់ចាយប្រាក់អឺរ៉ូ បម្រែបម្រួលភាគហ៊ុនប្រេងឆៅ API នៅសហរដ្ឋអាមេរិក ឥណទានវិស័យឯកជន និងការផ្តល់ប្រាក់កម្ចីវិនិយោគសម្រាប់លំនៅឋានរបស់ប្រទេសអូស្ត្រាលី ការផ្គត់ផ្គង់សាច់ប្រាក់ M២ របស់ប្រទេសឥណ្ឌូនេស៊ី តុល្យភាពថវិការបស់ប្រទេសបារាំង និងចំណូលពន្ធរបស់ប្រទេសអាហ្សង់ទីន៕

ខាងក្រោម គឺជាប្រតិទិនដែលនាយកដ្ឋានស្រាវជ្រាវថវិកានឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃចន្ទ ទី២៩ ខែមីនា ឆ្នាំ២០២១</u>

- ការផ្តល់ប្រាក់កម្ចីសុទ្ធដល់វិស័យឯកជន នៅចក្រភពអង់គ្លេស ធៀបនឹងខែមុន សម្រាប់ខែកុម្ភៈ
- ការផ្តល់ប្រាក់កម្ចីរបស់ធនាគារនៅប្រទេសប្រេស៊ីល ធៀបនឹងខែមុន សម្រាប់ខែកុម្ភៈ

<u>ថ្ងៃអង្គារ ទី៣០ ខែមីនា ឆ្នាំ២០២១</u>

- ការផ្គត់ផ្គង់សាច់ប្រាក់ M៣ នៅប្រទេសអាហ្វ្រិកខាងត្បូង ធៀបនឹងឆ្នាំមុន សម្រាប់ខែកុម្ភៈ
- ទស្សនៈឧស្សាហកម្មនៅតំបន់ចាយប្រាក់អឺរ៉ូ សម្រាប់ខែមីនា

<u>ថ្ងៃពុធ ទី៣១ ខែមីនា ឆ្នាំ២០២១</u>

- បម្រែបម្រួលភាគហ៊ុនប្រេងឆៅ API នៅសហរដ្ឋអាមេរិក សម្រាប់ថ្ងៃទី១៩ ខែមីនា
- ឥណទានវិស័យឯកជនរបស់ប្រទេសអូស្ត្រាលី ធៀបនឹងខែមុន សម្រាប់ខែកុម្ភៈ

<u>ថ្ងៃព្រហស្បតិ៍ ទី០១ ខែមេសា ឆ្នាំ២០២១</u>

- ការផ្តល់ប្រាក់កម្ចីវិនិយោគសម្រាប់លំនៅឋានរបស់ប្រទេសអូស្ត្រាលី សម្រាប់ខែកុម្ភៈ
- ការផ្គត់ផ្គង់សាច់ប្រាក់ M២ របស់ប្រទេសឥណ្ឌូនេស៊ី ធៀបនឹងឆ្នាំមុន សម្រាប់ខែកុម្ភៈ

ថ្ងៃសុក្រ ទី០២ ខែមេសា ឆ្នាំ២០២១

- តុល្យភាពថវិការបស់ប្រទេសបារាំង សម្រាប់ខែកុម្ភៈ
- ចំណូលពន្ធរបស់ប្រទេសអាហ្សង់ទីន សម្រាប់ខែមីនា